**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ២២០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

**ការធ្វើអនុបយោគកាត់ដី (១) ទំហំ ៦០៣,៥៧ ហិកតា ចេញពីគម្របព្រៃឈើ ២០០២ និង(២) ទំហំ ១៣២.០៨ ហិកតា ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន អាន ម៉ាឌី ដើម្បីធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ និងគោរពស្នើសុំប្រទានកម្មដីទំហំ ៣៧១,៤៩ ហិកតា ជំនួស សម្បទានសង្គមកិច្ច សម្រាប់ប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋសរុប ៦១៥ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ចំនួន ១.០៧៦ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ៦១៥ គ្រួសារ លើ ១.០៧៥ ក្បាលដី និងកម្មសិទ្ធិអវិភាគ ០១ ក្បាលដី (ទួលអប់ខ្មោច) នៅឃុំគគីរ និងឃុំត្រស់ ស្រុករមាសហែក ខេត្តស្វាយរៀង**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៤០ លស ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តស្វាយរៀង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.**

ត្រូវបានធ្វើអនុបយោគកាត់ដី (១)ទំហំ ៦០៣,៥៧ ហិកតា ចេញពីតម្របព្រៃឈើ ២០០២ និង(២) ទំហំ ១៣២.០៨ ហិកតា ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន អាន ម៉ាឌី (អនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែ តុលា ឆ្នាំ២០០៨) ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងប្រទានកម្មដីទំហំ ៣៧១,៩៩ ហិកតា ជំនួសសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋ ស្ថិតនៅក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម ៖

- ផ្ទៃដីទំហំ ១៤១,៤០ ហិកតា កាត់ចេញពីតម្របព្រៃឈើ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅភូមិគគីរ ឃុំគគីរ ស្រុករមាសហែក តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ
- ផ្ទៃដីសរុបទំហំ ៩៣០,៣៣ ហិកតា ក្នុងនោះកាត់ដី (១) ទំហំ ១០០,៩៩ ហិកតា ចេញពីតម្របព្រៃឈើ ២០០២ និង(២) ទំហំ ៨,៣៥ ហិកតា ពីដីក្រុមហ៊ុន អាន ម៉ាឌី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ (៣) ទំហំ ៣០០ ហិកតា ប្តូរពីដីសម្បទានសង្គមកិច្ចនៃអនុក្រឹត្យលេខ ១៦៦ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩ និង(៤) ទំហំ ២១,៩៩ ហិកតា ប្តូរពីដីសម្បទានសង្គមកិច្ចនៃអនុក្រឹត្យលេខ ១៦៧ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិ

បឹង ឃុំត្រស់ ស្រុករមាសហែក តាម ប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២)នៃអនុក្រឹត្យនេះ

- ផ្ទៃដីសរុបទំហំ ៥៣៥,៩១ ហិកតា ក្នុងនោះកាត់ដី (១) ទំហំ ៣៦១,៦៨ ហិកតា ចេញពីគម្រប ព្រៃឈើ ២០០២ (២) ១២៣,៧៣ ហិកតា ពីដីក្រុមហ៊ុន អាន ម៉ាឌី និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ និង(៣) ទំហំ ៥០ ហិកតា ប្តូពីដីសម្បទានសង្គមកិច្ចនៃអនុក្រឹត្យលេខ ១៦៦ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅភូមិត្រស់ ឃុំត្រស់ ស្រុករមាសហែក តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៣) នៃអនុក្រឹត្យនេះ។

**មាត្រា ២..**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តស្វាយរៀង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៦១៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិគគីរ ឃុំគគីរ និងភូមិបឹង ភូមិត្រស់ ឃុំត្រស់ ៖

- ផ្ទៃដីកាត់ចេញពីគម្របព្រៃឈើ ២០០២ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៣៣ គ្រួសារ នៅភូមិគគីរ ឃុំគគីរ ស្រុករមាសហែក
- ផ្ទៃដីកាត់ចេញពីគម្របព្រៃឈើ ២០០២ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧០ គ្រួសារ និងពីដីក្រុមហ៊ុន អាន ម៉ាឌី ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១១ គ្រួសារ (៣) ដីប្តូពីដីសម្បទានសង្គមកិច្ចនៃអនុក្រឹត្យលេខ ១៦៦ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៥៣ គ្រួសារ និង(៤) ដីប្តូពីដីសម្បទានសង្គមកិច្ចនៃអនុក្រឹត្យលេខ ១៦៧ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ០៦ គ្រួសារ នៅភូមិបឹង ឃុំត្រស់ ស្រុករមាសហែក
- ផ្ទៃដីកាត់ចេញពីគម្របព្រៃឈើ ២០០២ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៥០ គ្រួសារ (២) ពីដីក្រុមហ៊ុន អាន ម៉ាឌី ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៧៦ គ្រួសារ និង(៣) ដីប្តូពីដីសម្បទានសង្គមកិច្ចនៃអនុក្រឹត្យលេខ ១៦៦ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៦ គ្រួសារ នៅភូមិត្រស់ ឃុំត្រស់ ស្រុករមាសហែក

**មាត្រា ៣ ..**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិសរុបចំនួន ១.០៧៦ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ៦១៥ គ្រួសារ លើចំនួនក្បាលដី ១.០៧៥ ក្បាលដី និងដីអវិភាគ ០១ ក្បាលដី (ទួលកប់ខ្មោច) ដែលស្ថិតនៅក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៣៣ គ្រួសារ លើក្បាលដីចំនួន ១៦៧ ក្បាលដី នៅភូមិគគីរ ឃុំ គគីរ ស្រុករមាសហែក

- ផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៣៦៣ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ២៨០ គ្រួសារ លើក្បាលដីចំនួន ៣៦២ ក្បាលដី និងដីអវិភាគ ០១ ក្បាលដី (ទួលកប់ខ្មោច) នៅភូមិបឹង ឃុំត្រស់ ស្រុករមាសហែក
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៨២ គ្រួសារ លើក្បាលដីចំនួន ៥៨៦ ក្បាលដី នៅភូមិត្រស់ ឃុំត្រស់ ស្រុករមាសហែក ។

**មាត្រា ៤ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តស្វាយរៀង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ ធ្នូ ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*




592000
594000
596000
598000
600000
1267000
1268000
1269000
1270000
1271000
1272000


សញ្ញាសំគាល់
ចំណុចបង្គោលព្រំដី
ដីដែលប្រជាពលរដ្ឋកំពុងកាន់កាប់មាន ចំនួន ៤៣០,៣៣ ហិកតា
មាត្រដ្ឋាន1:32,000
2,000
0
Meters
N
588000
590000
592000
594000
1271000
1272000
1273000
1274000
1275000